# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៤ អនក្រ.បក

លិខិតចូល
ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៨
14

## អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដីចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ " មណ្ឌលគិរី "

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "មណ្ឌលគិរី"

- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានកាត់ចេញនូវផ្ទៃដីទំហំ ៥៦.៤៦៧ ហិកតា ពីក្នុងតំបន់ ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ " មណ្ឌលគីរី " ដូចមានចែងនៅក្នុងមាត្រា៣នៃអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ និងមានផែនទីខ្នាត ១:៤០០.០០០ ភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយ បណ្តុំចំណុចគោលដែលមាននិយាមកា : A (៧៣២៦៦២, ១៤០០៧០៧), B (៧៧២១៤៧,១៤០០៧០៧), C (៧៦៦៣០៧, ១៣៨៥៥៣៧), D (៧៧០១៣៨, ១៣៧០៥៧២), E (៧៥៩២១២, ១៣៦៧៣៦២), F (៧៥៨៤៨២, ១៣៨៥៤០៥), G (៧៥៧៧០៣, ១៣៨៨៤២៥), H (៧៤២៦៨៣, ១៣៨៨៤០២), I (៧៣៧១២៩, ១៣៩៣៥៥០), J (៧៣៦៣៦៣, ១៣៩៨០៥៥), K (៧៣១៨៥៥, ១៣៩៣៤៣៦) ។

**មាត្រា ២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលាខេត្តមណ្ឌលគីរី ចុះកំណត់រៀបចំផ្ទៃដីដែលកាត់ចេញពីតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគីរី" នេះ ដើម្បីប្រើប្រាស់ក្នុងកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច និង សម្បទានដីសេដ្ឋកិច្ច ទៅតាមនីតិវិធី រួចដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច លើកលែងតែព្រៃស្រោង និងពាក់កណ្តាលស្រោងដែលត្រូវថែរក្សា ការពារជាចាំបាច់ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

ចន់ សារុន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ